01684544



នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Nov-21, 09:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ថ្នាក់ឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញាអន្តរជាតិ**
លោកស្រី Brenda J. HOLLIS

**ចម្លងជូន:**
**សហព្រះរាជអាជ្ញាជាតិ**
លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម Chandra Nihal JAYASINGHE
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម Florence N. MWACHANDE-MUMBA
ចៅក្រម Maureen HARDING CLARK
ចៅក្រម យ៉ា ណារិន

**ជនជាប់ចោទ**
ខៀវ សំផន

**មេធាវីការពារក្តី**
គង់ សំអុន
Anta GUISSÉ

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
លោក ពេជ អង្គ
លោកស្រី Megan HIRST

# ចម្លើយតប

1. សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.ព”) ឆ្លើយតបទៅនឹងសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យអង្គជំនុំជម្រះតុលាការកំពូលធ្វើការសម្រេចទាក់ទងនឹងការធ្វើចំណាត់ប្រភេទឯកសារឡើងវិញទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី[1]។

2. ដូចសហមេធាវីនាំមុខបានសង្កេតដែរ ការធ្វើចំណាត់ប្រភេទឡើងវិញតម្រូវឱ្យមានការថ្លឹងថ្លែងយ៉ាងប្រុងប្រយ័ត្នលើផលប្រយោជន៍ និងជាបញ្ហាដ៏មួយដែលសំខាន់ខ្លាំង។ ស.ព.អ កត់សម្គាល់ថា ការថ្លឹងថ្លែងអំពីអត្ថប្រយោជន៍នេះ តម្រូវឱ្យមានមិនត្រឹមតែដើមបណ្តឹងរដ្ឋប្បវេណីប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសម្រាប់ជនជាប់ចោទ សាក្សី និងសាក្សីសក្ខីនុពលដែលបានចូលរួមក្នុងកិច្ចដំណើរការនីតិវិធីផងដែរ។ ស.ព.អ គាំទ្រសំណើរបស់សហមេធាវីនាំមុខ ដែលសុំឱ្យមានការណែនាំពីអង្គជំនុំជម្រះ ពាក់ព័ន្ធនឹងវិធីដែលភាគីអាចចូលរួមចំណែកក្នុងដំណើរការ ជាពិសេសក្នុងការការពារព័ត៌មានរសើប និងឯកជនក្នុងសំណុំរឿង ០០២ ក៏ដូចជាក្នុងសំណុំរឿងផ្សេងទៀត។

3. ផ្អែកលើមូលហេតុនេះ ស.ព.អ មានបំណងដាក់សំណើសុំធ្វើចំណាត់ប្រភេទឯកសារឡើងវិញរបស់ខ្លួនទៅកាន់អង្គជំនុំជម្រះនៅសប្តាហ៍ក្រោយ។ ទោះបីសំណើនេះនឹងស្នើឱ្យធ្វើចំណាត់ប្រភេទឯកសារឡើងវិញនូវឯកសារសំណុំរឿង ០០៤/២ យ៉ាងណាក្តី គោលដៅសំខាន់គឺដើម្បីជួយសម្រួលដល់ការអភិវឌ្ឍគោលការណ៍ និងនីតិវិធីឱ្យកាន់តែទូលំទូលាយ ដែលនឹងធានាថា ការធ្វើចំណាត់ប្រភេទឡើងវិញនៅ អ.វ.ត.ក នឹងត្រូវបានអនុវត្តដោយប្រុងប្រយ័ត្ន និងមានសង្គតិភាពនៅទូទាំងសំណុំរឿងទាំងអស់។

4. ស.ព.អ សង្ឃឹមថា អង្គជំនុំជម្រះនឹងអនុញ្ញាតឱ្យភាគីទាំងអស់ចូលរួមក្នុងដំណើរការធ្វើចំណាត់ប្រភេទឡើងវិញ ដើម្បីឱ្យឯកសាររបស់តុលាការនេះ អាចត្រូវបានធ្វើឱ្យទៅជាសាធារណៈ និងរកបានជាសាធារណៈបានច្រើនតាមដែលអាចធ្វើបាន ខណៈពេលជាមួយគ្នា ក៏ត្រូវមានការការពារព័ត៌មានរសើប និងផ្ទាល់ខ្លួនរបស់បុគ្គលដែលបានចូលរួមចំណែកយ៉ាងក្លាហានដល់ការងាររបស់ អ.វ.ត.ក។ មានតែការកំណត់តុល្យភាពត្រឹមត្រូវរវាងគោលការណ៍ទាំងពីរនេះប៉ុណ្ណោះ ទើប អ.វ.ត.ក នឹងសម្រេចបានកេរដំណែលមួយដែលមានតម្លៃពិតប្រាកដសម្រាប់យកជាគម្រូ៕

[1] ឯកសារ **F71** សំណើរសុំការសម្រេចពាក់ព័ន្ធនឹងការធ្វើចំណាត់ប្រភេទឡើងវិញ ទៅលើឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២១។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ | **លោកស្រី** **Brenda J. HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |